## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ: ៤១៩១ មស.ត្រា

ថ្ងៃ ចន្ទ ១៤ រោច ខែ បឋមាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០២០

**សូមគោរពជូន**

**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន**
**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**
**លោក លោកស្រី អភិបាលនៃគណៈអភិបាល ក្រុង ស្រុក ខណ្ឌ**

**កម្មវត្ថុ** ៖ ស្តីពីការធ្វើប្រក្រតីភាពការផ្ទេរក្របខ័ណ្ឌ ឬផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការនៅថ្នាក់ក្រោមជាតិឡើងវិញ។
**យោង** ៖ លិខិតលេខ ៦០១៦ មស.ត្រ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងលោក លោកស្រី អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មេត្តាជ្រាបថា កន្លងមកក្រសួងមុខងារសាធារណៈ បានចេញលិខិតលេខ ៦០១៦ មស.ត្រ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការផ្អាកការផ្ទេរក្របខ័ណ្ឌ ឬផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ ក្នុងពេលកំពុងដំណើរការនៃការរៀបចំផ្ទេររចនាសម្ព័ន្ធនិងបុគ្គលិកឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយផ្អែកលើតម្រូវការ និងសំណូមពរការងារចាំបាច់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រសួងមុខងារសាធារណៈសូមធ្វើការណែនាំពីការធ្វើប្រក្រតីភាពឡើងវិញលើការផ្ទេរក្របខ័ណ្ឌ ឬផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការដូចខាងក្រោម៖

១- អនុញ្ញាតឱ្យធ្វើប្រក្រតីភាពឡើងវិញចំពោះការផ្ទេរក្របខ័ណ្ឌ ឬផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការដែលបម្រើការងារនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ មន្ត្រីរាជការនៃមន្ទីរអង្គភាពជំនាញនានាដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

២- អនុញ្ញាតឱ្យធ្វើប្រក្រតីភាពឡើងវិញចំពោះការផ្ទេរក្របខ័ណ្ឌ ឬផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការដែលបម្រើការងារនៅរដ្ឋបាលរាជធានី ខេត្ត។

៣- ផ្អាកការផ្ទេរចេញពីរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទៅមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ជាតិ រហូតដល់មានការសម្រេចជាថ្មី។ ប៉ុន្តែរដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចធ្វើការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការរវាងអង្គភាពមួយទៅអង្គភាពមួយទៀត ព្រមទាំងការតែងតាំង ឬប្រគល់ភារកិច្ចមន្ត្រីរាជការនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌសាមី ដោយអនុលោមតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងលោក លោកស្រី អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មេត្តាជ្រាប និងទទួលនូវការគោរពពីខ្ញុំ។

**រដ្ឋមន្ត្រី**

ប្រាំ សុខា

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

ផ្លូវវេងអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh